GC LIFE



# ត្រូវការបន្ថែម ការការពារមែនទេ ?

## ធានារ៉ាប់រងបន្ថែមជាក្រុម សម្រាប់ការព្យាបាលដោយគ្រោះថ្នាក់ជាយថាហេតុ - ការសម្រាកព្យាបាលនៅមន្ទីរពេទ្យ

## កម្មវត្ថុនៃការធានារ៉ាប់រង

ការសម្រាកព្យាបាលនៅមន្ទីរពេទ្យរបស់អ្នកត្រូវបានធានារ៉ាប់រង។

## លក្ខខណ្ឌនៃការបង់បុព្វលាភ

| | |
|---|---|
| វិធីសាស្រ្តបង់បុព្វលាភ | ដូចទៅនឹងផលិតផលមូលដ្ឋាន |
| មធ្យោបាយបង់បុព្វលាភ | ការផ្ទេរប្រាក់តាម App ឬគណនីធនាគារ សាច់ប្រាក់ មូលប្បទានបត្រ |
| ការបំពាន | ដូចទៅនឹងផលិតផលមូលដ្ឋាន |

## វិសាលភាពនៃការធានារ៉ាប់រង

ផលិតផលនេះផ្តល់នូវការធានាទៅលើការចំណាយវេជ្ជសាស្រ្តលើការសម្រាកព្យាបាលនៅមន្ទីរពេទ្យដោយគ្រោះថ្នាក់ជាយថាហេតុរបស់អ្នកត្រូវបានធានារ៉ាប់រងក្នុងអំឡុងពេលដែលការធានារ៉ាប់រងរបស់គាត់កំពុងមានសុពលភាព។

## អត្ថប្រយោជន៍ និងបុព្វលាភធានារ៉ាប់រង

| អត្ថប្រយោជន៍ធានារ៉ាប់រង | | |
|---|---|---|
| ក្នុងករណីអ្នកត្រូវបានធានារ៉ាប់រងជួបគ្រោះថ្នាក់ជាយថាហេតុក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបណ្តាលឲ្យកើតមានការសម្រាកព្យាបាលនៅមូលដ្ឋានសុខាភិបាលណាមួយក្នុងព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុននឹងទូទាត់សំណងធានារ៉ាប់រងដោយផ្អែកទៅតាមការកំណត់ដូចមានចែងក្នុងតារាងនេះ៖ | ចំណាយលើបន្ទប់សម្រាកធម្មតា | 100% |
| | ចំណាយលើបន្ទប់ ICU | 100% |
| | ចំណាយព្យាបាលលើការវះកាត់ | 100% |
| | ចំណាយលើរថយន្តសង្គ្រោះបន្ទាន់ | 100% |
| | ចំណាយលើថ្លៃថ្នាំ ដែលប្រើប្រាស់ក្នុងអំឡុងពេលធ្វើរោគវិនិច្ឆ័យ (រួមបញ្ចូលទាំងថ្លៃចំណាយលើការពិគ្រោះជំងឺក្រៅក្នុងរយៈពេល ៧២ម៉ោងមុនចូលសម្រាកនៅមន្ទីរពេទ្យ) | 100% |
| | ចំណាយលើការស្កេន X-ray, ECG, ការពិនិត្យដោយប្រើប្រាស់ឧបករណ៍ផ្សេងៗ និងការប្រើប្រាស់បន្ទប់ពិសោធន៍ (រួមបញ្ចូលទាំងថ្លៃចំណាយលើការពិគ្រោះជំងឺក្រៅក្នុងរយៈពេល ៧២ម៉ោងមុនចូលសម្រាកនៅមន្ទីរពេទ្យ) | 90% |
| | ចំណាយលើថ្លៃថ្នាំ ដែលមិនពាក់ព័ន្ធនឹងការធ្វើរោគវិនិច្ឆ័យ | 85% |
| | ចំណាយលើការព្យាបាលផ្សេងៗ | 80% |

បុព្វលាភធានារ៉ាប់រងនឹងត្រូវកំណត់ផ្អែកទៅតាមមុខរបរ ប្រភេទការងារ អាយុ ប្រវត្តិស្ថានភាពសុខភាពរបស់អ្នកត្រូវបានធានារ៉ាប់រង និងចំនួនមនុស្សដែលនឹងត្រូវធានា។

| គម្រោង Platinum អតិបរមានៃសំណង | គម្រោង Gold អតិបរមានៃសំណង | គម្រោង Sliver អតិបរមានៃសំណង |
| --- | --- | --- |
| $1,000 | $500 | $300 |

## ករណីមិនធានា

១.ក្រុមហ៊ុនធានារ៉ាប់រងនឹងមិនមានទំនួលខុសត្រូវក្នុងការផ្តល់សំណងធានារ៉ាប់រងឡើយ ប្រសិនបើនៅពេលដាក់ពាក្យស្នើសុំ អ្នកស្នើសុំធានារ៉ាប់រងមិនបានជូនដំណឹងពិតដល់ក្រុមហ៊ុន មានការលាក់បាំងអំពីស្ថានភាពសុខភាពដែលមានសភាពមិនល្អរបស់អ្នកត្រូវបានធានារ៉ាប់រង ដូចករណីរៀបរាប់ខាងក្រោមៈ

(១)អ្នកត្រូវបានធានារ៉ាប់រងបានធ្វើរោគវិនិច្ឆ័យរកឃើញថាមានជំងឺរ៉ាំរ៉ៃមួយ ឬច្រើនប្រភេទ ឬជំងឺស្រួចស្រាវ ឬជំងឺសតិអារម្មណ៍

(២)អ្នកត្រូវបានធានារ៉ាប់រងមានពិការភាព ឬមុខងារនៃភ្នែក ឬត្រចៀក ឬចលនារាងកាយមានភាពមិនប្រក្រតី

(៣)អ្នកត្រូវបានធានារ៉ាប់រងប្រកបមុខរបរមានហានិភ័យខ្ពស់ដែលក្រុមហ៊ុនមិនអាចធានាបាន

(៤)អាយុពិតប្រាកដរបស់អ្នកត្រូវបានធានារ៉ាប់រងនៅពេលដែលកិច្ចសន្យាបានបង្កើតមិនសមស្របតាមអាយុសម្រាប់ ដាក់ពាក្យស្នើសុំដូចបានចែងក្រោម ខ និងលក្ខខណ្ឌក្នុងកិច្ចសន្យាធានារ៉ាប់រង។

២.ព្រឹត្តិការណ៍ផ្សេងៗនៃ“ករណីមិនធានា”ដែលបានចែងក្នុងផលិតផលមូលដ្ឋាន(“គម្រោងការពារខ្លួន”ជាក្រុម)។

៣.ចំណាយសម្រាប់ការព្យាបាលដែលបណ្តាលមកពីជំងឺ។

ចំណាំៈ ខិតប័ណ្ណផ្សព្វផ្សាយនេះគឺជាការពណ៌នាដោយសង្ខេប។ សម្រាប់ព័ត៌មានលម្អិត សូមអាន ខ និងលក្ខខណ្ឌធានារ៉ាប់រង។ ក្នុងករណីដែលកើតមានភាពមិនស៊ីចង្វាក់គ្នា ត្រូវយក ខ និងលក្ខខណ្ឌធានារ៉ាប់រងជាគោល។